

# ពីកំណើត ដល់ ប្រាំមួយឆ្នាំ

## ការលូតលាស់និងការរីកចំរើន

**សូមសួរ**

ទារកមិនអាច
រង់ចាំបានទេ

### អ្វី
ក្រដាសតារាងនេះត្រូវគេសរសេរសំរាប់ឪពុក/ម្តាយ ប៉ុន្តែនរណាដែលដឹងនិងធ្វើការជាមួយកូនរបស់អ្នកនឹងអាចយកវាជាជំនួយបាន ។

### ហេតុអ្វី
ក្រដាសតារាងនៃការពិនិត្យសំរាំងជាមុននេះជារបៀបលឿនមួយសំរាប់ជួយអ្នកឲ្យដឹងពីផ្នែកដែលប្រហែលមានបញ្ហានៅក្នុងការមើល, ការស្តាប់, និងការលូតលាស់របស់ក្មេង ។ ក្រដាសតារាងនេះ នឹងជួយអ្នកឲ្យពិនិត្យបញ្ហាលើក្មេងទាំងមូល ។ អ្នកនឹងត្រូវឃ្លាំមើលការរីកចំរើនលូតលាស់របស់ក្មេង នៅក្នុងផ្នែកខាងជំនាញការខាងគិត, ប្រស្រ័យទាក់ទង, ស្តាប់, និយាយ, ហើយនិងសកម្មភាពធ្វើចលនា ។ ជំនាញការខាងចលនាខ្លះប្រើសាច់ដុំតូចៗ (ដូចជាម្រាមដៃ) ជំនាញការខាងចលនាឯទៀតប្រើសាច់ដុំធំ (ដូចជាជើង) ។ ជាការសំខាន់ណាស់ដែលត្រូវប្រយ័ត្នចំពោះការមើល និងការស្តាប់សំរាប់ក្មេងគ្រប់អាយុ ។ សំខាន់! ក្រដាសតារាងនេះជារបៀបលឿនមួយសំរាប់ជួយអ្នករក្សាឃ្លាំមើល, ការស្តាប់, និងការលូតលាស់របស់ក្មេង ហើយវាមិនមែនមានបំណងធ្វើជាការធ្វើតែសខាងការរីកចំរើនការវិនិច្ឆ័យតម្លៃ និងការប៉ាន់ប្រមាណទេ ។

### របៀបណា
ជំពូកនៃអាយុនិមួយៗមានចុះពីសកម្មភាពដែលក្មេងភាគច្រើននឹងអាចធ្វើបាននៅពេលណាមួយក្នុងរវាងឆ្នាំទីមួយនិងឆ្នាំទីពីរនៅក្នុងជំពូកនៃអាយុនោះ ។ ឧទាហរណ៍ នៅពេលមានអាយុ 12 ខែ, ក្មេងភាគច្រើននឹងអាចធ្វើសកម្មភាពទាំងអស់ដែលចុះនៅក្រោមជំពូកនៃអាយុពី 6 ទៅ 12 ខែ។ ទោះជាយ៉ាងនេះក្តី ក្មេងភាគច្រើនមិនអាចធ្វើសកម្មភាពទាំងអស់នេះនៅអាយុ 6 ខែបានទេ ។ ការដូចគ្នានេះគឺជាការពិតនៅក្នុងជំពូកនៃអាយុនិមួយៗ ។ ដូច្នេះកុំឲ្យខ្វល់ខ្វាំងពេកបើក្មេងដែលមានអាយុនៅដើមខែនៃជំពូកនៃអាយុមួយ ហើយមិនអាចធ្វើសកម្មភាពទាំងអស់បាននោះ ។ ដោយក្មេង មានការលូតលាស់តាមកំរិតខុសគ្នា ចូរកុំជ្រួលច្របល់ពីព្រោះតែក្មេងហាក់ដូច ជាចេះដឹងមិនទាន់អាយុនោះ ។

ចូរមើលសកម្មភាពដែលគេចុះនៅក្រោមជំពូកអាយុរបស់ក្មេង
និងនៅក្រោម ជំពូកការមើលឃើញនិងការស្តាប់ឮ ។
ឃ្លាំមើលនិងស្តាប់ក្មេងនៅខណ:ពេលវា កំពុងលេង ។
តើក្មេងធ្វើសកម្មភាពឬទេ? គឺជាការសំខាន់ដែលក្មេងមានពេល, កន្លែងទូលាយនិងសម្ភារ:ដែលត្រូវការសំរាប់សកម្មភាពនិមួយៗ ។ ឧទាហរណ៍ កុំនិយាយថាក្មេងនេះមិនអាចគូររូបមុខបានបើអ្នកមិនឲ្យក្រដាសនិងខ្មៅដៃ ឬពណ៌ក្រមួនទៅវាទេនោះ ។
អ្នកអាចចង់ឃ្លាំមើលនិងស្តាប់ក្មេងជាច្រើនថ្ងៃ
ដោយប្រើតារាងកត់ចំណាំការ បារម្ភណាមួយដែលអ្នកអាចមាន ។
បើក្មេងនៅកំរិតអាយុថ្នាក់លើនៃជំពូកមួយ មិនអាចធ្វើសកម្មភាពទាំងអស់ទេ គ្រួសារអាចរួមចំណែកការសង្កេតរបស់ពួក គេជាមួយអ
្នកមានវិជ្ជាជីវ:ដែលអាចមើលដោយយកចិត្តទុកដាក់នូវការរីកចំរើន
របស់ក្មេង ។

### ពេលណា
ឃ្លាំមើលនិងស្តាប់ក្មេងពេលវាកំពុងលេង ។ អ
្នកត្រូវរកមើលនូវអ្វីដែលក្មេងចូល ចិត្តជាធម្មតា ។
កុំប្រើក្រដាសតារាងនេះពេលណាក្មេង ឈឺ, នឿយ ហត់, ឬមួម៉ៅ ។

### អ្វីបន្ទាប់ទៅទៀត
អ្នកអាចទូរស័ព្ទទៅលេខសំរាប់ខាងកម្មវិធី ម្តាយមានសុខភាពល្អកូនក៏មានសុខភាពល្អ ដែលមានលេខចុះនៅខាងក្រោមដើម្បីរកលេខសំរាប់ Lead Family Resource Coordinator (FRC) នៅក្នុងតំបន់អ
្នក បើអ្នកមានការ ចាប់អារម្មណ៍អំពីការលូតលាស់របស់កូនអ្នក ។
វេជ្ជបណ្ឌិតកូនរបស់អ្នក, ក្រសួងសុខាភិបាល ឬមណ្ឌលសិក្សាអាចជួយអ
្នកនិងឪពុក/ម្តាយរកទីភ្នាក់ងារ
នៅជិតដែលអាចធ្វើការពិនិត្យនូវការលូតលាស់របស់ក្មេង, ការមើល, និង/ឬ ការស្តាប់ឲ្យជិតដល់បាន។

### ការមើល តើកូនរបស់អ្នក ...
- ☐ ធ្វើការទាក់ទងតាមភ្នែក (មើលភ្នែករបស់អ្នក)
- ☐ បើកភ្នែកតាមមើលរបស់មានចលនា
- ☐ ដើរ ឬវារដោយគ្មានជំពប់លើរបស់អ្វីមួយ
- ☐ មើលទៅមនុស្ស ឬរបស់ដោយភ្នែកទាំងពីរ
- ☐ កាន់យួររបស់បានចំងាយធម្មតា (ក្រោយអាយុ ៦ ខែ)
- ☐ ដើរ ឬវារដោយស្រួលកាត់ទីងងិត ឬទីកន្លែងដែលហាក់ដូចខុសគ្នា (កំរាល, ឥដ្ឋក្រាល)
- ☐ មើលទៅមនុស្ស ឬរបស់ដោយមិនចាំបាច់ធ្វើភ្នែកស្រលៀងមើលតាម ឬបើកភ្នែកព្រឹមៗ(ក្រោយ ៩ខែ)
- ☐ មានភ្នែកភ្លឺថ្លា មិនក្រហម ឬចេញទឹកភ្នែក

### ការស្តាប់ តើកូនរបស់អ្នក ...
- ☐ បង្ហាញពីការដែលដឹងនូវសំឡេងក្នុងផ្ទះ(ទូរស័ព្ទ, សម្លេងគោះទ្វារ, ទូរទស្សន៍)
- ☐ ប្រើសំឡេងដែលមិនខ្លាំងពេក មិនទន់ពេក
- ☐ លេងជាមួយល្បែងដែលធ្វើឲ្យមានសំឡេង (អង្រ្គន់, កណ្តឹង)
- ☐ ធ្វើត្រាប់តាមសំឡេង (ក្រោយពី ១ ឆ្នាំ)
- ☐ ប្រើពាក្យដែលចប់ដោយខ្យល់ "s" ឬ "ing" ក្រោយអាយុ ២ ឆ្នាំ
- ☐ ធ្វើតាមពាក្យណែនាំដោយមាត់ទទេ
- ☐ ចេះបើកសំឡេងទូរទស្សន៍ ឬវិទ្យុឲ្យតិចល្មម
- ☐ ស្តាប់រឿង កាសែតចំរៀង ឬទូរទស្សន៍ដោយគ្មានការលំបាក
- ☐ និយាយក្នុងរបៀបដែលមនុស្សភាគច្រើនអាចយល់បាន (បើអាយុក្រោម 2 ឆ្នាំកន្ទះ)
- ☐ ដើរសំដៅមកអ្នក ពេលណាហៅពីបន្ទប់ផ្សេង (ក្រោយអាយុ 2 ឆ្នាំ)

*Funding by the Department of Early Learning*

Washington State Department of Early Learning

Our web address is:
www.del.wa.gov/esit

Early Support for Infants and Toddlers

DEL 11-002 CA (02/11)

Family Health Hotline
1.800.322.2588
711 (tty relay) • withinreachwa.org
a program of WithinReach

# ពីកំណើត ដល់ ប្រាំមួយឆ្នាំ

## ការលូតលាស់និងការរីកចំរើន



**សំរាប់មាតាបិតា៖** ក្នុងនាមជាមាតាបិតា អ្នកជាជនសំខាន់បំផុតសំរាប់ជីវិតរបស់កូនអ្នក ។ អ្នកស្គាល់កូនរបស់អ្នកច្បាស់ជាងគេ ។ បើអ្នកមានការបារម្ភពីការរីកចំរើនរបស់កូនរបស់អ្នក អ្នកអាចស្នើសុំការវិនិច្ឆ័យតម្លៃមួយបាន ។ សូមសួរបើអ្នកមានសំនួរឬមានការបារម្ភ ។ ចូរទូរស័ព្ទទៅកម្មវិធី ម្តាយមានសុខភាពល្អទារកក៏មានសុខភាពល្អដែរតាមលេខ 1-800-322-2588 ដើម្បីរកឈ្មោះរបស់ប្រភពអ្នក សំរបសំរួលគ្រួសារតាមតំបន់របស់(FRC) ដែលអាចជួយអ្នកបាន។



**សំរាប់អ្នកផ្តល់ការព្យាបាល៖** ក្មេងធំលូតលាស់និងរីកចំរើនក្នុងរបៀបខុសៗគ្នា ។ សូមព្យាយាមនិងនិយាយទៅកាន់គ្រួសារអំពីការរីកចំរើនរបស់កូនចៅគេជាទៀងទាត់ ។ សួរពួកគេពី ជំនាញការថ្មីអ្វីដែលកូនចៅរបស់ពួកគេបាន រៀនចេះដឹងបញ្ហាអ្វីដែលពួកគេអាចមាន និងរួមចំណែកការសង្កេតឃើញផ្ទាល់ខ្លួនរបស់អ្នក ។ ចូរប្រាប់ឲ្យគ្រួសារដឹងថាបើពួកគេពិតជាមានការបារម្ភមែន មានពត៌មានបន្ថែមទៀតនិងជំនួយដោយទូរស័ព្ទទៅលេខម្តាយមានសុខភាពល្អទារកក៏មានសុខភាពល្អ (HM/HB) ពួកគេនឹងបញ្ជូនគ្រួសារនោះទៅប្រភពអ្នកសំរបសំរួលគ្រួសារតាមតំបន់របស់អ្នក (Family Resources Coordinator - FRC) អ្នកក៏អាចទូរស័ព្ទទៅ HM/HB ដើម្បីរកឈ្មោះនិងលេខទូរស័ព្ទរបស់ FRC ហើយរួមចំណែក ពត៌មានរនេះជាមួយនិងគ្រួសារនោះដោយផ្ទាល់តែម្តង ។

### ពីកំណើតរហូតដល់ 3 ខែ តើកូនរបស់អ្នក . . .

- ☐ ពេលផ្កាប់មុខប្រឹងងើបក្បាល និងពើងទ្រូង
- ☐ កម្រើកដៃ-ជើងយ៉ាងស្រួល
- ☐ ធ្វើតាមចលនារបស់អ្នកដោយប្រឹងងើយក្បាលពីម្ខាងទៅម្ខាង
- ☐ កាន់ដបទឹកដោះ ឬដោះមាតាដោយស្រួល ហើយជញ្ជក់ល្អ
- ☐ ភ្ញាក់ ឬឃំពេលឮសំឡេងខ្លាំងដោយចៃដន្យ
- ☐ ក្រឡេកមើលអ្នក មើលមុខអ្នក
- ☐ ធ្វើសំឡេងដូចក្រពុលមាត់ ឬថ្ងូរ
- ☐ ញញឹមឆ្លើយតបទៅនឹងការញញឹម ឬនិយាយរបស់អ្នក
- ☐ ឆាប់នៅស្ងៀមពេលណាត្រូវគេលួង

### 3 ទៅ 6 ខែ តើកូនរបស់អ្នក . . .

- ☐ លេងជាមួយជើងរបស់គេពេលណាដេកផ្ងារ
- ☐ ងើយក្បាលនិងទ្រូងដោយប្រើទម្ងន់លើដៃពេលណាផ្កាប់ពោះ
- ☐ ងើបក្បាលត្រង់ ហើយនៅនឹងដោយគ្មានជួយទ្រ
- ☐ រមៀលពីពោះទៅខ្នង ហើយពីខ្នងទៅពោះ
- ☐ លេងដៃខ្លួនឯងដោយប៉ះដៃទាំងពីរជាមួយគ្នា
- ☐ ឈោងយកប្រដាប់ក្មេងលេង
- ☐ ចាប់យកប្រដាប់ក្មេងលេងដែលដាក់នៅជិតដៃ
- ☐ ងាកក្បាលរេតាមរកមើលសំឡេង
- ☐ ធ្វើឲ្យឮសំឡេងខុសគ្នាច្រើនយ៉ាង
- ☐ សើចឮខ្លាំង
- ☐ ព្យាយាមបង្ហាញនូវការចូលចិត្ត ឬមិនចូលចិត្ត

### 6 ដល់ 12 ខែ តើកូនរបស់អ្នក . . .

- ☐ ងើបឈរខ្លួនឯងដោយមានការជួយខ្លះៗ
- ☐ អង្គុយដោយគ្មានការជួយខណ:ពេលលេងជាមួយប្រដាប់ក្មេងលេង
- ☐ ផ្លាស់របស់ពីដៃមួយទៅដៃមួយ
- ☐ កាន់របស់ញាំុនិងដៃបានដោយខ្លួនឯង
- ☐ ធ្វើត្រាប់ការបក់ដៃ លាហើយ
- ☐ ឲ្យអ្នកដឹងអំពីសេចក្តីត្រូវការរបស់គេដោយប្រើចលនា និងសំឡេង
- ☐ ធ្វើត្រាប់តាមសំឡេងនិយាយ (បា-បា/កា-កា)
- ☐ ដូរវេនខណ:កំពុងលេងជាមួយមនុស្សធំ (សកម្មភាព, សំឡេង, ឬការបញ្ជាក់ទឹកមុខ)
- ☐ ប្រាប់អ្នកឲ្យដឹងថាគេយល់សំនួរងាយៗ ("តើអ្នកចង់បានទៀតទេ?")
- ☐ ស្គាល់ឪពុក/ម្តាយរវាងអ្នកចំឡែក

### 12 ដល់ 18 ខែ តើកូនរបស់អ្នក . . .

- ☐ ដើរម្នាក់ឯង
- ☐ រើសរបស់តូចៗ (ប៉ុនទំពាំងបាយជូរក្រៀម)
- ☐ ដាក់របស់ចូលនិងចាក់ចេញពីធុង
- ☐ ដាក់របស់មួយពីលើរបស់មួយទៀត
- ☐ ញាំបាយខ្លួនឯងដោយប្រើស្លាបព្រា
- ☐ និយាយពាក្យពីរ-បីខុសគ្នាបន្ថែមពីលើពាក្យ "ម៉ា-ម៉ា " ឬ "ដាដា"
- ☐ សួររករបស់ដោយប្រើពាក្យផ្សេងៗ
- ☐ កាន់កែវ ហើយផឹកទឹកពីកែវដោយមានកំពប់បន្តិចបន្តួច
- ☐ ចង្អុលទៅរបស់ជាច្រើន ឬរូបភាពពេលណាឲ្យប្រាប់ឈ្មោះ

### 18 ខែដល់ 2 ឆ្នាំ តើកូនរបស់អ្នក . . .

- ☐ ដើរចុះឡើងជណ្តើរដោយឲ្យគេកាន់ដៃ
- ☐ គូសក្រវើមក្រវ៉ាម
- ☐ ប្រើចលនាខ្លួនត្រូវតាមភ្លេង
- ☐ ប្រើពាក្យពីរម៉ាត់បញ្ចូលគ្នា ("ទឹកជូសថែមទៀត")
- ☐ ចាប់ផ្តើមសួរសំនួរ "ទឹកជូស?" "លាហើយ?"
- ☐ កាន់សាន់វិច្ឆខាំញាំុដោយខ្លួនឯង
- ☐ ដោះស្រោមជើងនិងស្បែកជើង
- ☐ មើលសៀវភៅរឿងរូបភាពជាមួយមនុស្សធំ
- ☐ ធ្វើការជ្រើសរើសងាយៗក្នុងចំណោមល្បែងលេង (រូបប្រស្នា ឬឡានត្រ័ក)
- ☐ ធ្វើត្រាប់តាមក្មេងដ៏ទៃៗទៀតដែលលេង (ចាក់ខ្សាច់, បោះបាល់)

### 2 ឆ្នាំដល់ 3 ឆ្នាំ តើកូនរបស់អ្នក . . .

- ☐ ដើរនឹងល្អ, រត់, ឈប់, ចង្អើតជើង, និងអង្គុយចោងហោង
- ☐ ដាក់របស់គរលើគ្នាលើសពីបី
- ☐ ប្រើស្លាបព្រា និងសមដោយខ្លួនវា
- ☐ ធ្វើតាមពាក្យណែនាំពីរយ៉ាង ("យកសៀវភៅហើយដាក់នៅ លើតុ")
- ☐ រាប់ផ្នែកនៃដងខ្លួន 5-6 មុខនៅលើខ្លួនវា
- ☐ ចូលរួមក្នុងការសន្ទនាងាយស្រួល
- ☐ ឆ្លើយសំនួរងាយដូចជា "ស្អី" និង "តើស្អី" ("តើអ្នកចង់ញាំុស្អីពេលបាយ?")
- ☐ ចង្អុល ឬប្រាប់ឈ្មោះរបស់ពេលណាប្រាប់ការប្រើ ("តើអ្នកផឹកដោយប្រើអ្វី?")
- ☐ ជួយធ្វើការងាយ (ដូចជារើសប្រដាប់ក្មេងលេង)
- ☐ ប្រើឃ្លាដែលមានពាក្យ 2-3 ម៉ាត់ជាទៀងទាត់រាល់ថ្ងៃ

### 3 ឆ្នាំដល់ 4 ឆ្នាំ តើកូនរបស់អ្នក . . .

- ☐ លោត, រត់, ក្រវែង, ស្រវ៉ាឡើង ដោយមានលំនឹងល្អ
- ☐ គូររង្វង់មូល, បន្ទាត់និងខ្វែងដោយប្រើខ្មៅដៃពណ៌
- ☐ ប្រើប្រដាប់ប្រដារ និងប្រដាប់ក្មេងលេងដើម្បីធ្វើជាដើរតួ
- ☐ ចូលចិត្តរូបភាពក្នុងសៀវភៅ ហើយចូលចិត្តឲ្យគេមើលឲ្យស្តាប់
- ☐ យល់នូវពាក្យដែលប្រាប់កន្លែងរបស់ដូចជា (ក្រោយ, ក្រោម, ក្នុង, លើ)
- ☐ ប្រើពាក្យនិយាយដែលងាយស្តាប់
- ☐ សួរសំនួរជាច្រើនអំពី "ហេតុអី" និង "ស្អី"
- ☐ ចូលចិត្តលេងជាមួយក្មេងដ៏ទៃទៀត
- ☐ ពេលខ្លះចាំវេនរបស់ខ្លួន
- ☐ ឆ្លើយសំនួរងាយៗពី "ឯណា" និង "អ្នកណា"

### 4 ឆ្នាំដល់ 5 ឆ្នាំ តើកូនរបស់អ្នក . . .

- ☐ លេងល្បែងដាំដូង ឬល្បែងណាដែលប្រើសាច់ដុំធំៗ (ដូចជាជើង)
- ☐ លោតជើងកុបៗ
- ☐ គូររូបមុខបានដូចមុខបេះបិត
- ☐ ចេះស្លៀកពាក់ខ្លួនឯងដោយការជួយបន្តិចបន្តួច
- ☐ សួរសំនួរដោយប្រើពាក្យ "ស្អី, ឯណា, នរណា, និង ហេតុអី"
- ☐ និយាយត្រូវសំឡេងស្ទើរតែគ្រប់ពាក្យលើកលែងតែ " s, z, th, និង r"
- ☐ ប្រើពាក្យបង្ហាញអំពីទំហំ និងលេខ (ធំ, ចំនួន)
- ☐ ប្រាប់ទាំងនាមត្រកូល និងនាមខ្លួន
- ☐ ចូលចិត្តលេងជាមួយក្មេងដែលមានអាយុដូចគ្នា

### 5 ឆ្នាំដល់ 6 ឆ្នាំ តើកូនរបស់អ្នក . . .

- ☐ ចូលចិត្តចាប់, ក្រវែង, ទាត់បាល់
- ☐ មានលំនឹងល្អពេលណាលេងល្បែងប្រើសាច់ ដុំធំ (លេងញេច, លេងដាំដូង, បាល់វាយដំបង)
- ☐ ចូលចិត្តកាត់របស់ដោយប្រើកន្ត្រៃ
- ☐ ស្លៀកពាក់ខ្លួនឯងដោយចេះបិតឡេវ, កិប, ហើយរូត)
- ☐ បង្ហាញការចូលចិត្តដោយពាក្យសរសេរ
- ☐ និយាយដូចជាពាក្យសំដីគ្រួសារ (ប្រើពាក្យ និងឃ្លាប្រភេទដូចគ្នា)
- ☐ ធ្វើតាមការប្រាប់បីមុខតាមលំដាប់ដែលគេបង្គាប់ ("យកបាល់, ដាក់វានៅក្នុងប្រអប់ដាក់ប្រដាប់ប្រដារលេង, ហើយមកឯតុវិញ។")
- ☐ ប្រាប់ឈ្មោះពេញ, អាយុ ហើយភេទរបស់វា
- ☐ ចូលចិត្តលេងល្បែងរៀបចំស្រួលជាមួយក្មេងឯទៀតៗ (ល្បែងសែម៉ុននិយាយ, ល្បែងញេច)

**សូមសួរ**

**ទារកមិនអាចរង់ចាំបានទេ**